*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៦៩ អនក្រ**
**ស្តីពីការផ្ទេរសណ្ឋាគារវិមានរដ្ឋចំការមន**
**ជូនទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់គ្រង**

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់សម្តេចក្រុមឃុន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១** .- ផ្ទេរសណ្ឋាគារវិមានរដ្ឋចំការមន រួមទាំងចលនវត្ថុ និង អចលនវត្ថុទាំងអស់អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២** .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួង និង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះ ហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***